# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ០៥៩ ព.ណ.កព.ប្រក

# ប្រកាស
## ស្តីពី
## ការធ្វើប្រតិភូកម្មការគ្រប់គ្រង រៀបចំ និងចាត់ចែងព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្ម ក្នុងព្រះរាជាណាចក្រកម្ពុជា ជូនមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/ ០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនាឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយ សម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសរួមលេខ១២១៧ សហវ.ប្រក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញប្រកាសលេខ០៧៥ ពណ.កព.ប្រក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការគ្រប់គ្រងការរៀបចំ និងចាត់ចែងព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្ម ក្នុងព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ១.-**

ត្រូវបានធ្វើប្រតិភូកម្មការគ្រប់គ្រង ការរៀបចំ និងចាត់ចែងព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្មក្នុងព្រះរាជាណាចក្រកម្ពុជាដែលមានចំនួនចាប់ពី ៥០(ហាសិប)ស្តង់ចុះ ជូនមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ក្នុងគោលបំណងបង្ខិតការបម្រើសេវាវិស័យពាណិជ្ជកម្មឱ្យទៅកៀកពាណិជ្ជករ អាជីវករ សេវាករនៅថ្នាក់ក្រោមជាតិ។



ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

**ប្រការ២ .-**

មន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត មានភារកិច្ចពិនិត្យ និងផ្តល់លិខិតអនុញ្ញាតជូនអ្នកស្នើសុំរៀបចំព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្ម ប្រកបដោយភាពទទួលខុសត្រូវខ្ពស់ ស្របតាមខ្លឹមសារនៃប្រកាសស្តីពីការគ្រប់គ្រង ការរៀបចំ និងចាត់ចែងព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្មក្នុងព្រះរាជាណាចក្រកម្ពុជា។

បន្ទាប់ពីបានចេញលិខិតអនុញ្ញាតជូនអ្នកស្នើសុំឱ្យរៀបចំព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្ម មន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ត្រូវរាយការណ៍អំពីប្រធានបទ កាលបរិច្ឆេទ និងទីតាំងនៃការរៀបចំព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្ម យ៉ាងតិច ០៧(ប្រាំពីរ)ថ្ងៃ មុនព្រឹត្តិការណ៍ចាប់ផ្តើម ព្រមទាំងផ្តល់របាយការណ៍មិនឱ្យលើសពី ០៧(ប្រាំពីរ)ថ្ងៃ បន្ទាប់ពីព្រឹត្តិការណ៍ត្រូវបានបិទបញ្ចប់ ជូននាយកដ្ឋានកិច្ចការពិព័រណ៍ នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម។

**ប្រការ៣ .-**

មន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ត្រូវសហការជាមួយនាយកដ្ឋានកិច្ចការពិព័រណ៍ នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្នុងការតាមដាន និងចុះត្រួតពិនិត្យការរៀបចំព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្ម ដែលបានចេញលិខិតអនុញ្ញាតជូន។

**ប្រការ៤ .-**

អ្នកស្នើសុំរៀបចំព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្ម ដែលមានចំនួនពី ៥០(ហាសិប)ស្តង់ចុះ ត្រូវដាក់ពាក្យស្នើសុំនៅមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត និងមានកាតព្វកិច្ចអនុវត្តន៍តាមខ្លឹមសារទាំងស្រុង នៃប្រកាសលេខ០៧៥ ព.ណ.ក.ព.ប្រក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការគ្រប់គ្រងការរៀបចំ និងចាត់ចែងព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្មក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៥ .-**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានគ្រប់អង្គភាពពាក់ព័ន្ធ ប្រធានមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៩ កើត ខែ ផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២ ខែមីនា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

ព្រះរាជាណាចក្រកម្ពុជា

ក្រសួងពាណិជ្ជកម្ម

**ប៉ាន សូរស័ក្តិ**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៥
- ឯកសារ កាលប្បវត្តិ